**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១១៨
ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៨
**សាលដីកា**
លេខៈ១១៥
ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ........... ជាចៅក្រមរបាយការណ៍
៤-លោក ............ ជាចៅក្រម
៥-លោក ............ ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ................

**តំណាងមហាអយ្យការ**

-លោក .................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំនះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧១០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៩៩៧ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឃព ភេទស្រីអាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅភូមិឧត្តម ឃុំព្រៃកខ្យាយ ។ ស្រុកពាមរក៍ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ បគ (ស)ម្តាយឈ្មោះ ឃល (ស ) ប្តីឈ្មោះ ហក ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ធសថ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ ក្រណាត់ មានទីលំនៅផ្ទះលេខ២០៥Eo ផ្លូវលេខ១៦៣ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ហក(ស) ម្តាយឈ្មោះ ហទ(ស) នៅលីវ ។

មានមេវិលោក .................

**កម្មវត្ថុបណ្តឹង** ប្តឹងទាមទារចំណែកកេរ្តិ៍មរតក

បានឃើញបណ្តឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី ឃព បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ៧១០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១១៨ ចុះថ្ងៃទី២៧ ខែមេសាឆ្នាំ១៩៩៨ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១៧-០២-១៩៩២ របស់ដើមចោទឈ្មោះអ្នកស្រី ឃព ថា ខ្លួនសុំទាមទារឱ្យបែងចែកកេរ្តិ៍មរតក ដែលនៅសល់ពីខ្មោចប្ដីខ្លួន ព្រោះថាទ្រព្យសម្បត្តិផ្ទាល់ខ្លួន មានមុនពេល រៀបការ គឺចំនួន១០ដំឡឹង លុះក្រោយពេលរៀបការហើយ ទ្រព្យសម្បត្តិរួមមានចំនួន៣២១ ដំឡឹង ហេតុនេះ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ផង ។

បានឃើញសាលក្រមលេខ៨៤ (ក) ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១៧-០២-៩២ របស់ដើមចោទឈ្មោះ ឃព ទុកជាត្រឹមត្រូវ តាមទម្រង់ តែបដិសេធចោលដោយខុស និងគតិច្បាប់ ។

២- បង្គាប់ឱ្យឈ្មោះ ឃព បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣០០០រៀល រង្វាន់សាក្សី២០០០រៀល បូករួម៧០០០រៀលប្រាក់នេះត្រូវកាត់យកពីប្រាក់៧.០០០រៀលដែលដើមចោទបានបង់ទុករួចជាស្រេច ។

៣- សាលគ្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី ហើយសម្រេចបើកផ្លូវឧរណ៍រយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ២៨ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៥ របស់អ្នកស្រី ឃព ដែលប្ដឹងជំទាស់នឹងសាលក្រមលេខ៨៤(ក)ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៥ របស់តុលាការ ក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៥ ចុះថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចចាត់របៀប :

១- បង្គាប់ឱ្យគូភាគីផ្ដល់ភស្តុតាងបញ្ជាក់ថា ប្រពន្ធដើមរបស់ឈ្មោះ ហក នៅមុនពេលស្លាប់ តើបានមករស់នៅលើផ្ទះលេខ២០៥Eo ផ្លូវ១៦៣ សង្កាត់ទួលទំពូង២ ខណ្ឌចំការមនក្រុងភ្នំពេញ ដែរឬទេ ?

២- ចាត់ឱ្យការិយាល័យសុរិយោដីក្រុងភ្នំពេញ វាយតម្លៃផ្ទះលេខ២GEo ផ្លូវ១៦៣សង្កាត់ទួលទំពូង២ ខណ្ឌចំការមន ក្រុងភ្នំពេញ តាមតម្លៃផ្សារសេរីឱ្យបានត្រឹមត្រូវ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧១០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលា ឧទ្ធរណ៍ សម្រេចចំពោះមុខចុងបណ្ដឹងខ្ទរណ៍ កំបាំងមុខដើមបណ្ដឹងឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ របស់នាងឃឹម ពៅ ចុះថ្ងៃទី០៦-០៥-១៩៩៥ ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៤៤(ក) ចុះថ្ងៃទី០៥-០៤-១៩៩៥ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣- ទទួលពាក្យបណ្ដឹងសុំទាមទារទ្រព្យរួមរបស់នាង ឃព ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៤. ទទួលពាក្យបណ្ដឹងទាមទារមរតកឱ្យកូនទាំង០៣នាក់ទុកជាត្រឹមត្រូវជាមទម្រង់និងគតិច្បាប់។

៥- បង្គាប់ឱ្យឈ្មោះ ហសថ ប្រគល់ប្រាក់ជាមរតករបស់សពឈ្មោះ ហក ទៅឱ្យកូននៃសពឈ្មោះ ហសណ ភេទស្រី កើតឆ្នាំ១៩៨៥ ហសខ ភេទប្រុស កើតឆ្នាំ១៩៨៧ និងហេង សុខា ភេទប្រុស កើតឆ្នាំ១៩៩១ ក្នុងម្នាក់ៗ ចំនួន ៤.០៣៥ ដុល្លាអាមេរិក ( សរុបមរតក នៃកូនទាំងបីនាក់នេះស្មើនឹង ១២.១០៥ ដុល្លាអាមេរិក) ហើយប្រាក់នេះ ត្រូវប្រគល់ឱ្យឈ្មោះ ឃព ជាម្ដាយ និងជាអាណាព្យាបាល កាន់កាប់ និងថែរក្សាជាប្រយោជន៍ នៃកូនជាអនីតិជនទាំងបីនាក់ខាងលើ ។

ចំណែកមរតក ដែលនៅសល់ត្រូវបានជាចំណែកស្មើគ្នាដល់កូនឈ្មោះ ហសថ និង ហសណ ។

៦- កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០រៀល គឺពន្ធហ្នឹង និងពន្ធចុះបញ្ជី ក្ដី ២.៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហើបប្រាក់៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ៥០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

៧- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងបណ្ដឹងឧទ្ធរណ៍ កំបាំងមុខដើម បណ្ដឹងឧទ្ធរណ៍ បើកផ្លូវប្ដឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់

បានឃើញបណ្ដឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី ឃព បានប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៧១០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៩-០២-១៩៩៩ របស់ឈ្មោះ ឃព

បានឃើញសារណាតប ចុះថ្ងៃទី១៧-០៨-១៩៩៩ របស់ឈ្មោះ ហសថ

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់ណាងមហាអយ្យការថា គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

សាលដីកាលេខ៧១០ ចុះថ្ងៃទី០១-១២-៩៧ របស់សាលាឧទ្ធរណ៍ សម្រេចមកនេះមានការខុសឆ្គងទាំងទម្រង់ និងទាំងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាសម្រេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ឃព ជាដើមចោទ និងម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា មកពីសាលាឧទ្ធរណ៍ ចែកផ្ទះឱ្យមិនត្រឹមត្រូវ ដោយផ្ទះនេះជាកម្មសិទ្ធិរបស់ខ្លួនផ្ទាល់ ព្រោះផ្ទះនេះខ្លួនបានចូលមករស់នៅតាំងពីឆ្នាំ៨៥ មកម្ល៉េះ ខ្លួនសូមឱ្យបែងចែកតាមយុត្តិធម៌ ព្រមទាំងក្រុមហ៊ុន

ដែលចាប់ដំណើរការនៅឆ្នាំ១៩៨៦ ពេលប្តីស្លាប់គេបានផ្ទេរសិទ្ធិឱ្យកូនឈ្មោះ ឈស ក្រុមហ៊ុននេះ គឺមានដើមទុនរបស់ខ្លួនពិតប្រាកដ តាំងពីមានមួយហ៊ុនចំនួន១៥តម្លឹង រហូតដល់មានចំនួន ១០០តម្លឹង តាំងពីពេលនោះមក មិនដែលមានការខាតបង់ទេ ។ ក្រោយមកខ្លួន បានទៅខ្ចីប្អូនថ្លៃចំនួន៥ ,២តម្លឹង ដើម្បីយកទៅថែមហ៊ុនទៀត ការចូលហ៊ុននេះគឺមិនបានសរសេរជាកិច្ចសន្យាទេ ឯហ៊ុនផ្សេងទៀត ជាអ្នកដទៃ មិនមែនជាប់សាច់ឈាមអ្វីនឹងគ្នាទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ហសថ ជាចុងចម្លើយ និងចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ផ្ទះពិតជាមានមែនតែជាផ្ទះរបស់ឪពុក-ម្តាយ និងជីដូនរបស់ខ្លួន ដែលបានមកស្នាក់នៅតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ដែលមានភូមិ-ឃុំទទួលស្គាល់តាមច្បាប់ទាំងអស់ ។ ចំពោះក្រុមហ៊ុននេះនៅដំណើរការនៅឡើយដោយឪពុកខ្លួនជាអ្នកឈរឈ្មោះនៅតុលាការក្រុង គេបានហៅសមាជិកមកសួរដែរហើយ ក៏ពួកគេមកធ្វើជាសាក្សីទៀត ។ ការផ្ទេរសិទ្ធិមានមែន តែជាការរកស៊ីតូចតាចទេ បើក្រុមហ៊ុននេះមិនបានផ្ទេរឱ្យគាត់ទេ ព្រោះក្នុងក្រុមហ៊ុនគេមានលក្ខន្តិកៈ របស់គេត្រឹមត្រូវណាស់ ការផ្ទេរនេះមិនមែនផ្ទេរភាគហ៊ុនទេតែគាត់បានផ្ទេរតែកន្ទុយក្រណាត់ដែលនៅសល់តែប៉ុណ្ណោះ ក្រណាត់ នេះគាត់ទិញហើយ ផ្ញើនៅផ្ទះគេ រួចគាត់ក៏ផ្ទេរឱ្យខ្លួនលក់បន្តទៀត ហ៊ុននេះខ្លួនមិនដឹងថាមានប៉ុន្មានទេ ខ្លួនគ្រាន់តែដឹងថា បានប្រគល់ក្រណាត់ដែលនៅសល់ឱ្យមកខ្លួនលក់ប៉ុណ្ណោះ ក្រណាត់នេះគាត់ដាក់ផ្ញើនៅក្នុងក្រុមហ៊ុន សេងហុង ហើយគេក៏បាន បញ្ជាក់ថា ក្រណាត់នៅសល់ត្រូវប្រគល់មកឱ្យខ្លួនជាកូន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោក .......... បញ្ជាក់ថា អ្នកស្រី យព បាន រៀបអាពាហ៍ពិពាហ៍ តាំងពីយូរមកហើយ កូនក្តីរបស់ខ្ញុំបាទបានគ្រប់គ្រងកូនប្រពន្ធមុន ២នាក់ និងកូនក្រោយ ២នាក់ទៀត ការរៀបអាពាហ៍ពិពាហ៍គឺមានច្បាប់ត្រឹមត្រូវស្របទៅតាមមាត្រា៣៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ដូច្នេះផ្ទះ ត្រូវក្លាយជាទ្រព្យរួមសំបាច់របស់ប្តីប្រពន្ធ ពេលគាត់ស្លាប់ទៅ( ហក ) ក៏កើតឡើងអំពីវិវាទមរក ។ សាលាឧទ្ធរណ៍បានចែកផ្ទះឱ្យប្រពន្ធពាក់កណ្តាល ហើយពាក់កណ្តាលទៀតត្រូវបានទៅកូនឈ្មោះ ហសថ ខ្ញុំបាទយល់ឃើញ ថាការបែងចែកនេះមិនត្រឹមត្រូវទេ ព្រោះផ្ទះនេះអ្នកស្រី យព បាននៅឆ្នាំ ១៩៨៥ នៅពេលនោះផ្ទះនេះជាទ្រព្យសម្បត្តិ របស់រដ្ឋនៅឡើយ ជាមការវាយតម្លៃផ្ទះនេះ មានតំលៃ ៤០៣០០ដុល្លា ដូច្នេះសបញ្ជាក់ថា ប្តីព្រន្ធរស់នៅជាមួយគ្នាជាយូរមកហើយ មិនមានទ្រព្យសម្បត្តិរួមសោះនោះ មិនត្រឹមត្រូវទេ ឯចំណែកភាគហ៊ុនគឺមានតែអ្នកស្រី យព ដែលជាកូន ក្តីរបស់ខ្ញុំបាទ និងលោកហកដែលពីការចូលហ៊ុនគ្នារកស៊ីនេះ ។ ដូច្នេះការអះអាងរបស់កូនក្តីខ្ញុំបាទគឺជាការត្រឹមត្រូវ សូមលោកប្រធានតុលាការកំពូលសម្រេចបែងចែកទ្រព្យជាថ្មីតាមគតិយុត្តិធម៌ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ.

-ក្រោយពីបានពិភាក្សត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១១-១២-៩៧ របស់អ្នកស្រី យព ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលអ្នកស្រី យព លើកឡើងក្នុងសារណា ចុះថ្ងៃទី ០៩-០២-៩៩ ថា អ្នកស្រីទាមទារយកបន្ថែមនូវចំណែកពាក់កណ្តាលទៀតនៃផ្ទះ ដែលតុលាការបានបែងចែកជាមរតកឱ្យកូននៃសពអ្នកស្រី ហទ ជាភរិយាដើម នៃសពលោក ហក នោះជាការពុំត្រឹមត្រូវទេ ពីព្រោះផ្ទះនេះជាទ្រព្យសម្បត្តិដើមរួមគ្នារបស់សពលោក ហក និងសពអ្នកស្រី ហទ ដែលបានកាន់កាប់មុនពេលដែលអ្នកស្រីរៀបអាពាហ៍ពិពាហ៍ជាមួយសពលោក ហក នៅឆ្នាំ១៩៨៥ ។

-យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលមិនបានលើកយកភាគហ៊ុននៅក្នុងក្រុមហ៊ុនក្រណាត់យីហោ សេង ហុង មកធ្វើការបែងចែកឱ្យអ្នកស្រី យព និងកូន សំអាង ហេតុថា សពលោក ហក ពុំមានភាគហ៊ុននៅក្នុងក្រុមហ៊ុននេះទេ នោះជាការភ័ន្តច្រឡំ ពីព្រោះថា សាឡឹឈ្មោះ តអអ ឈ្មោះ ផយ និង ឈ្មោះ សស បញ្ជាក់ថា ពិតជាមានភាគហ៊ុន ក្នុងក្រុមហ៊ុននេះ ហើយនៅពេលដែលលោក ហក ស្លាប់ឈ្មោះ ហសថ បានទៅឈរលក់ត្រណាត់ ក្នុងឃ្លាំងនោះថែមទៀត ។ ម៉្យាងទៀត តាមការបកប្រែលើខិតជាភាសាចិន ចុះថ្ងៃទី១៥-១២-៩០និង១៨-០១-៩១ ( ឯកសារ១៩/១ ១៩/២ ) បានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនក្រណាត់នេះ ត្រូវបានលោក ហក ផ្ទេរទៅឱ្យឈ្មោះ ឈស ហៅ ហសថ មុនពេលដែលគាត់ស្លាប់មែន ។ ដូច្នេះប្រាក់អាជីវកម្មក្រណាត់នេះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមសម្បាច់ រវាងសពលោក ហក និង អ្នកស្រី យព ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧១០ ចុះថ្ងៃទី០១-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ហើយលើកលែងតែចំណុចទី៣ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខច្ចក្ត

១_ ទទួលបណ្តឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី យព ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

២- តម្កល់ សាលដីការដ្ឋប្បវេណីលេខ៧១០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី៣ នៃសាលដីកានេះ ដែលត្រូវទុកជាមោឃៈ ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១១៨ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ត្រង់ចំណុចទី៣ នៃសេចក្តីសម្រេច ។

៤. រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រី ឃព បានបង់រួចហើយ គឺ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ថា រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០រៀល ហើយតម្រូវឱ្យ លោក ហសថ សងប្រាក់ចំនួន១៩០០០រៀល នេះទៅអ្នកស្រី ឃព វិញ ។

បង្គាប់ឱ្យលោក ហសថ បង់ពន្ធសមាមាត្រ១% លើទឹកប្រាក់១២.១០៥ ដុល្លាអាមេរិក។

៥. សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ ។